# AS WE FAIL

There's a saying that states that you have two hands: one for helping yourself and the other for helping others.

This mantra has stayed with this 22-year-old woman, Estelí Mariana Garcia, all her life. Estelí or Ellie, a graduate in psychology and biology, applied for a fellowship program in Princeton Asia to find a job of her best fit—teaching—which turned out to be in Liger Leadership Academy, Cambodia.

When asked why Cambodia, she replied, "I didn't pick Cambodia, I picked Liger; I knew right away that's what I'm going to do."

Ellie grew up in Seattle, Washington, United States, after her parents moved from Bolivia. Her dad works for Hispanic communities to help them navigate their resources in the US. Meanwhile, her mom works as a social worker with unaccompanied minors or refugees to get funding for their colleges or to find pathways for their lives.

Everything that her parents did influenced who Ellie is today; "Watching them as I grow up became really important that I also have a job that I can be a part of someone's life", she said.

But, how do we ride on a seesaw balancing the wants of helping others and the necessity of keeping our life together?

Being enrolled in a university is where competition comes in; Ellie had to compete with hundreds of students to be in a neurobiology major, but unfortunately, she didn't succeed. It was that point when her life got all cobbled up and that she hit rock bottom.

When you fail, that's when you realize the bigger picture. Cindy Liu, 22, a graduate from Princeton University, applied to the Liger Leadership Academy through a Princeton Asia fellowship, also experienced the similar dilemma.

"Everyone has been successful up until college, you know that you can't always be on top", Cindy said. "[You realized] that there are always people who are better than you", she continued.

Regardless, there is always a silver lining behind every cloud. This motto is what motivates a 22-year-old man, Jakub Kukiella, another applicant to Liger Leadership Academy, to stay in university after having his back broken and being paralyzed for a few weeks. He thought that he had failed and that he would never walk again.

He used to be a carefree person and did not take school so seriously. He then became aware that it’s not how life works. After experiencing this affliction, he came to realize that he can't comport the same way anymore; he opted for change.

Jakub has a better appreciation in life after this event; he has gained better insights into his life and that there is more incredible stuff waiting for him out there! As for Ellie, she ended up doing a double major in her university life! For her, it is about being resilient; she knows that she has to push through and do the next best thing. To do that, she started to value what she has more and focused on being grateful for the

little things in life. Cindy has become more self-aware and that it is important for her to quash the idea of comparison with others.

Collectively, the focus of their lives shifted from the act of humanity to the subsistence of each life. All of them have gone through arduous circumstances, however, they still show us that we all are apt to twist and turn our lives around because it's never too late.

"Every time something bad happens, it's when [we are] turning more into ourselves," Ellie concluded.

These three are just a few examples of how intelligent our facilitators are academically and how successful they are in life. There are so many other inspiring and amazing stories carved in every Liger facilitator and the examples above are just from our newest ones.

By Rika Chan

# នៅពេលដែលយើងបរាជ័យ

មានពាក្យស្លោកមួយពោលថា យើងមានដៃពីរ មួយសម្រាប់ជួយខ្លួនឯង និង មួយទៀតសម្រាប់ជួយអ្នកដ៏ទៃ។

គំនិតមួយនេះតែងតែនៅជាប់ជាមួយកញ្ញាម្នាក់ឈ្មោះ អេលលី ព្រោះជីវិតរបស់នាង មានតម្លៃដោយសារការជួយយកអារសារអ្នកដ៏ទៃ។

អេលលីគឺជាសិស្សម្នាក់ដែលបានបញ្ចប់ការសិក្សាផ្នែកជីវវិទ្យា និងចិត្តសាស្ត្រ។ បន្ទាប់ពីបញ្ចប់ការសិក្សាមក កញ្ញាបានដាក់ពាក្យដើម្បីស្វែងរកការងារជាគ្រូបង្រៀននៅសាលាភាពជាអ្នកដឹកនាំឡៃហ្គី ដែលស្ថិតនៅប្រទេសកម្ពុជាយើងនេះ។

នៅពេលដែលសំណួរមួយបានលើកឡើងថា "ហេតុអ្វីបានជាកញ្ញាជ្រើសរើសប្រទេសកម្ពុជា?" កញ្ញាបានតបថា *"ខ្ញុំមិនបានជ្រើសយកប្រទេសកម្ពុជានោះទេ ខ្ញុំជ្រើសយកសាលានេះផ្ទាល់តែម្តង ព្រោះសាលានេះផ្តោតទៅលើអ្វីដែលខ្ញុំចង់ធ្វើ។"*

កញ្ញាអេលលីធំធាត់ឡើងនៅរដ្ឋវ៉ាស៊ីនតោន សហរដ្ឋអាមេរិក បន្ទាប់ពីគ្រួសាររបស់នាងបានរើចេញពីប្រទេសបូលីវា។ ឪពុករបស់នាង ធ្វើការឲ្យសកលវិទ្យាល័យផ្សេងៗ ព្រមទាំងជួយជនជាតិអេស្ប៉ាញក្នុងការជួយស្វែងរកគោលដៅនាថ្ងៃអនាគតរបស់ពួកគេ។ ចំណែកឯម្តាយរបស់នាងវិញ គឺជាអ្នកបំរើការងារ សង្គមជាមួយកុមារ និងជនភៀសខ្លួន ដើម្បីជួយពួកគេ ក្នុងការស្វែងរកមូលនិធិសម្រាប់សកលវិទ្យាល័យ ឬស្វែងរកគោលដៅក្នុងជីវិត។

ការងាររបស់ឪពុកម្តាយអេលលីបានជះឥទ្ធពលយ៉ាងធំធេងមកលើនាង។ នាងបាននិយាយថា *"មើលអ្វីៗដែលពួកគេបានធ្វើនៅពេលខ្ញុំធំឡើង ធ្វើឲ្យខ្ញុំគិតថាវាពិតជាសំខាន់ណាស់សម្រាប់ខ្ញុំ ក្នុងការមានការងារមួយដែលខ្ញុំអាចជួយអ្នកដ៏ទៃដូចពួកគាត់"*។

តែហេតុអ្វីទើបយើងចង់ជួយអ្នកដទៃ ប្រសិនបើយើងមានជីវិតរបស់យើង ដែលត្រូវការការមើលថែ?

ការសិក្សានៅសកលវិទ្យាល័យ គឺជាពេលវេលាដែលតម្រូវឲ្យមានការប្រកួតប្រជែង។ អេលលីត្រូវប្រកួតជាមួយសិស្សានុសិស្សរាប់រយនាក់ទៀត ដើម្បីសិក្សាក្នុងថ្នាក់ប្រព័ន្ធប្រសាទវិទ្យា ប៉ុន្តែគួរឲ្យសោកស្តាយដែលនាងមិនត្រូវបានជ្រើសរើស។

នៅពេលដែលយើងបរាជ័យ គឺជាពេលដែលយើងយល់ដឹងពីអ្វីៗ ទាំងមូល។ កញ្ញា ស៊ីនឌី មានវ័យ ២២ ឆ្នាំ គឺជាសិស្សដែលបញ្ចប់ការសិក្សានៅសកលវិទ្យាល័យ Princeton ហើយក៏ជាមនុស្សម្នាក់ដែលបានដាក់ពាក្យមកសាលាភាពជាអ្នកដឹកនាំឡៃហ្គី និងជួបប្រទះរឿងស្រដៀងគ្នានេះដែរ។

នាងបាននិយាយថា *"សិស្សទាំងអស់ទទួលបានភាពជោគជ័យរហូតដល់ពេលដែលគាត់ចាប់ផ្តើមសកលវិទ្យាល័យ ហើយយើងដឹងថាយើងមិនអាចឈរនៅលេខមួយរហូតនោះទេ។"* នាងបានបន្តថា *"យូរៗទៅ យើងនឹងយល់ថា មានមនុស្សជាច្រើនអ្នកទៀតដែលមានសមត្ថភាពល្អជាងយើង។"*

*"ទោះជាយ៉ាងណាក៏ដោយ នៅលើលោកនេះមានអ្វីៗល្អៗ ច្រើនណាស់។"* ពាក្យស្លោកមួយនេះគឺជាអ្វីដែលលើកទឹកចិត្តបុរសម្នាក់ឈ្មោះ ចេឃឹប អាយុ ២២ ឆ្នាំ ឲ្យបន្តការសិក្សាទៅមុខទៀតបន្ទាប់ពីបានបាក់ខ្នង និងពិការ អស់រយៈពេលជាច្រើនសប្តាហ៍។ គាត់គិតថា គាត់បានបរាជ័យហើយ និងមិនអាចដើរបានតទៅទៀតនោះទេ។

គាត់គឺជាមនុស្សដែលមិនសូវយកចិត្តទុកដាក់ក្នុងសាលា ហើយអ្វីដែលគាត់គិតឃើញដល់គឺមានតែការជួបជុំមិត្តភក្តិដើម្បីជប់លៀង។ ប៉ុន្តែ បន្ទាប់ពីជួបរឿងរ៉ាវទាំងអស់នេះ គាត់ចាប់ផ្តើមគិតថាគាត់មិនអាចធ្វើបែបនេះតទៅទៀតទេ គាត់ត្រូវការភាពផ្លាស់ប្តូរ។

បន្ទាប់ពីបានហ្វឹកហាត់កាយសម្បទាឡើងវិញ ចេឃឺបមានការយល់ដឹងជ្រៅជ្រះទៅលើជីវិតរបស់គាត់កាន់តែប្រសើរជាងមុន ហើយឲ្យតម្លៃអ្វីៗ នៅជុំវិញគាត់។ ចំពោះអេលលីវិញ នាងបានបញ្ចប់ការសិក្សាផ្នែកជីវវិទ្យា និងចិត្តសាស្ត្រស្របតាមគោលបំណងរបស់នាង ហើយបានបន្តថា ការអត់ធ្មត់គឺសំខាន់ណាស់។ នាងដឹងថានាងត្រូវតស៊ូក្នុងជីវិត និងជុំរុញខ្លួនឯងឲ្យធ្វើអ្វីផ្សេងទៀត ព្រោះនៅថ្ងៃណាមួយនាងនឹងចាប់ផ្តើមឲ្យតម្លៃអ្វីៗដែលនាងមាន។ ចំណែកឯស៊ីនឌីវិញ នាងក្លាយជាមនុស្សម្នាក់ដែលយល់ដឹងពីខ្លួនឯងជាងមុន ហើយវាពិតសំខាន់ណាស់ ដែលនាងគួរតែ បោះចោលគំនិតនៃការប្រៀបធៀបខ្លួនឯង ជាមួយអ្នកដទៃ។

បទពិសោធន៍ខាងលើនេះបានឆ្លុះបញ្ចាំងការផ្លាស់ប្តូរពីការចង់ជួយអ្នកដទៃទៅការថែរក្សាជីវិតរបស់បុគ្គលម្នាក់។ ពួកគាត់ទាំងអស់ បានឆ្លងកាត់ស្ថានភាពលំបាកជាច្រើនប៉ុន្តែបទពិសោធន៍របស់ពួកគាត់ បានធ្វើឲ្យយើងឃើញថា យើងតែងតែអាចបត់បែនជីវិតរបស់យើងជានិច្ច ពីព្រោះវាសឹងតែគ្មានពាក្យថាហួសពេលពេកនោះទេ។

ជាចុងបញ្ចប់អេលលីបាននិយាយថា *“គ្រប់ពេលដែលអ្វីៗ ដែលមិនល្អកើតឡើង នោះគឺជាពេលដែលពួកយើងចាប់ផ្តើមបង្វែរអារម្មណ៍ មកលើខ្លួនឯង។”*

ដោយ ចន្ទ្រ រីកា